ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៩៤១៦ អជក.អក.ទល

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស **បុគ្គលិក** ចំនួន **៤២ រូប** ដើម្បីចូលបម្រើការងារនៅ តាមបណ្តាអង្គភាព នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

ក- **អង្គភាពបណ្តាញបញ្ជូន** សរុបចំនួន ៤១ រូប :

១- សម្រាប់ **បុគ្គលិកប្រចាំការអនុស្ថានីយ** (**អនុស្ថានីយកំពង់សីង្ហ** ចំនួន ០៨រូប, **អនុស្ថានីយប្រេកមាស** ចំនួន ០៨រូប, **អនុស្ថានីយបន្ទាយមាស** ចំនួន ០៥រូប, **អនុស្ថានីយតាកែវ** ចំនួន ០២រូប, **អនុស្ថានីយក្រុងព្រះសីហនុ** ចំនួន ០២ រូប, **អនុស្ថានីយស្ទឹងហាវ** ចំនួន ០២ រូប, **អនុស្ថានីយទី២** ចំនួន ០១ រូប, **អនុស្ថានីយទី៤** ចំនួន ០២ រូប និង **អនុស្ថានីយតាកែវ** ចំនួន ០១ រូប) សរុបចំនួន ៣១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E. III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានជាបង្គួរ ។

២- សម្រាប់ **បុគ្គលិកល្បាតខ្សែបញ្ជូន** ចំនួន ០៤ រូប, **បុគ្គលិកល្បាតខ្សែបញ្ជូនវាលវិញ-ស្ទឹងហាវ** ចំនួន ០១ រូប និង**បុគ្គលិកខណ្ឌថែទាំនិងជួសជុលខ្សែបញ្ជូន** ចំនួន ០៥រូប សរុបចំនួន ១០រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E. III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានជាបង្គួរ
- បេក្ខជន ត្រូវមានកាយសម្បទាមាំមួន ។

ខ- សម្រាប់ **បុគ្គលិករដ្ឋបាល ខណ្ឌរដ្ឋបាល នៃនាយកដ្ឋានបញ្ជូនអគ្គិសនី** ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឬ បរិញ្ញាបត្រគ្រប់គ្រង ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបានល្អ ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន សម្រាប់ **បុគ្គលិកប្រចាំការអនុស្ថានីយ** និង**បុគ្គលិកល្បាតខ្សែបញ្ជូនវាលវិញ-ស្ទឹងហាវ** ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព ។

*- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា បេក្ខជនត្រូវទាញយក( **Download** ) ដោយផ្ទាល់ពីក្នុងគេហទំព័រ របស់អគ្គិសនីកម្ពុជា គឺ : **www.EDC.com.kh** ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីអាជ្ញាធរដែនដី ចំនួន ០១ ច្បាប់
- តារាងពិន្ទុ ( TRANSCRIPT ) ចំនួន ០១ ច្បាប់

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។

*- **ទីកន្លែងទទួលពាក្យ** : នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

**កែវ_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។